## ស្តីអំពីការចូលប្រទេសជប៉ុនសារជាថ្មី

កាលពីថ្ងៃទី 11 ខែវិច្ឆិការដ្ឋាភិបាលជប៉ុនបានបើកឲ្យសិក្ខាកាមចូលមកកាន់ប្រទេសសារជាថ្មីដោយភ្ជាប់មកជាមួយលក្ខ័ណផ្សេងៗ។ក្រោយមកបានប្រទះឃើញមានភាពបំរែបំរួលនៅនឹងការព្រួយបារម្មណ៍ពីការឆ្លងរីករាលដាលនៅក្នុងពិភពលោកនៃមេរោគបំលែងថ្មី។អាស្រ័យហេតុនេះនៅថ្ងៃទី 30 ខែវិច្ឆិកាការចូលមកប្រទេសត្រូវបានផ្អាកសារជាថ្មី។
យើងនៅមិនទាន់ដឹងអំពីការបើកឡើងវិញម្តងទៀតនៃការចូលក្នុងប្រទេសជប៉ុននៅឡើយប៉ុន្តែយើងគិតថាសិក្ខាកាមបន្ទាប់ពីបើកការចូលឡើងវិញមិនមានការប្រែប្រួលអ្វីខ្លាំងនោះឡើយ។ខាងក្រោមនេះជាឯកសារយោង។

**ការចូលប្រទេសជាថ្មីត្រូវពិនិត្យឯកសារនឹងកាតស្នាក់នៅជាចាំបាច់។**

ការចូលប្រទេសជប៉ុនជាដំបូងសិក្ខាកាមទាំងអស់ត្រូវមានកាតសំគាល់ខ្លួនជាចាំបាច់។

ក្រៅពីនេះនៅមានឯកសារផ្សេងៗដូចជាសហាជីពដែលទទួលយកសិក្ខាកាមកិច្ចកុងត្រារវាងសិក្ខាកាមនិងសហាជីពឯកសារដែលបញ្ជាក់ផែនការនៃការរស់នៅផ្សេងៗសំរាប់ស្នើរទៅកាន់រដ្ឋាភិបាលដើម្បីត្រួតពិនិត្យជាចាំបាច់។

**អ្នកដែលចាក់វ៉ាក់សាំងពេញលេញការឃុំខ្លួននឹងត្រូវបន្ថយ**

សិក្ខាកាមដែលបានចូលមកក្នុងប្រទេសជប៉ុននឹងត្រូវបន្តការឃុំខ្លួននៅផ្ទះរយៈពេល14ថ្ងៃបន្ថែមទៀតជាកំហិត។ប៉ុន្តែនាបច្ចុប្បន្ននេះសំរាប់អ្នកដែលបានចាក់វ៉ាក់សាំងត្រឹមត្រូវហើយមានឯកសារបញ្ជាក់អវិជ្ជមានកូវីដនឹងត្រូវឃុំខ្លួននៅក្រោម10ថ្ងៃវិញ។

**អ្នកដែលទទួលបានលិខិតស្នាក់នៅនឹងបានចូលមកកាន់ប្រទេសជប៉ុនតាមលំដាប់**

ចំពោះអ្នកដែលទទួលបានឆាប់បានចូលមកកាន់ប្រទេសជប៉ុនមុន។មិនតែប៉ុណ្ណោះចំនួនអ្នកដែលអាចចូលមកប្រទេសជប៉ុនក្នុងមួយថ្ងៃគឺមានកំណត់។ការកំណត់បែបនេះគឺដើម្បីកាត់បន្ថយការរីករាលដាលនៃវីរុសកូវីដដូច្នេះ ហើយបច្ចុប្បន្ននេះអ្នកមិនអាចចូលមកកាន់ប្រទេសជប៉ុនបានភ្លាមៗនោះទេ។

## ការការពារពីជំងឺផ្តាសាយធំ (អ៊ីនហ្វ្លូអែនហ្សា)

នេះជារដូវដែលសម្បូរជំងឺផ្តាសាយនេះ។ទោះបីជំងឺនេះមានការថយចុះបើប្រៀបធៀបកាលពីឆ្នាំមុនមែនតែក៏មិនអាចនិយាយថាវាមានចំនួនតិចតួចនោះដែរ។ប្រសិនបើបើកប្រទេសវិញជំងឺផ្តាសាយធំនេះក៏អាចក្លាយជាពេញនិយមបានដែរ។

ក្រសួងសុខាភិបាលបានណែនាំអោយចាក់វ៉ាក់សាំងការពារជំងឺផ្តាសាយធំនេះយ៉ាងសកម្មបំផុតក្នុងឆ្នាំនេះ។

**វ៉ាក់សាំងជំងឺផ្តាសាយធំនិងវ៉ាក់សាំងកូវីដគឺមានគំលាត 2 សប្តាហ៍ដូចគ្នា។**

ក្រសួងសុខាភិបាលបានកំណត់ពីការទទួលវ៉ាក់សាំងជំងឺផ្តាសាយធំនិងវ៉ាក់សាំងកូវីដគឺចន្លោះនៃការចាក់ 2 សប្តាហ៍ដូចៗគ្នា។

ឧទាហរណ៏ប្រសិនបើអ្នកទទួលវ៉ាក់សាំងកូវីដនៅថ្ងៃទី5 ខែវិច្ឆិកា នោះ2 សប្តាហ៍ក្រោយថ្ងៃទី19 ខែវិច្ឆិកាជដែលអ្នកអាចទទួលវាក់សាំងការពារជំងឺផ្តាសាយធំបាន។

**ជាមូលដ្ឋានវ៉ាក់សាំងនេះគឺដូចគ្នានឹងវ៉ាក់សាំងកូវីដដែរ។**

ភាពចំបងនៃរោគសញ្ញាឆ្លងនឹងការចម្លងកូវីដនិងផ្តាសាយធំគឺមានសភាពដូចគ្នា។

- ឆ្លងតាមច្រមុះនិងមាត់ដោយការក្អកកណ្តាស់ទឹកមាត់ជាដើម
- មេរោគនៅជាប់នឹងដៃហើយយកទៅប៉ះមាត់ច្រមុះនិងភ្នែក

លាងដៃអោយបានញឹកញាប់ពាក់ម៉ាសនិងកុំជួបជុំគ្នាផ្សេងៗទាំងនេះជាវិធីសាស្រ្តរួមក្នុងការបង្ការការឆ្លងរីករាលដាល។

ប្រុងប្រយ័ត្នក្នុងរដូវរងារខាងមុខនេះបង្កើនការការពារជាមូលដ្ឋាននិងរក្សាសុខភាពទាំងអស់គ្នា។

## សហាជីពបានធ្វើការប្តូរស្លាកសញ្ញាថ្មី!

Asia Creation
アジアクリエーション協同組合

សហាជីពយើងខ្ញុំបានសំរេចប្តូរស្លាកសញ្ញាថ្មី។

វាជារចនាសម្ព័ន្ធដែលផ្គុំឡើងពីពាក្យថា「A」「C」「人」សហាជីពអាស៊ីក្រេតសិនបង្ហាញពីពាក្យថា「ស្វែងរកអនាគតនិងភ្ជាប់ទំនាក់ទំនងរវាងធនធានមនុស្សទៅនឹងក្រុមហ៊ុន」។

ស្លាកសញ្ញាបានសំរេចដោយផ្តោតទៅលើអនាគតភាពរុងរឿងការឈានទៅមុខការអភិវឌ្ឍន៍ដោយភ្ជាប់ជាមួយទំនុកចិត្តការជឿជាក់ភាពស្មោះត្រង់និងមានការចូលរួមពីបុគ្គលិកទាំងអស់ក្នុងសហាជីព

បុគ្គលិកទាំងអស់សុទ្ធតែយកចិត្តទុកដាក់ក្នុងការធ្វើការជារៀងរាល់ថ្ងៃ។

## ការចាប់ផ្តើមជីវភាពថ្មីនៃពលករជំនាញ



នៅក្នុងខែកុម្ភៈ ដើមឆ្នាំនេះមានសិក្ខាកាមជនជាតិវៀតណាម៣នាក់ដែលបានធ្វើការនៅក្រុមហ៊ុនស៊ីនកូហ្គុ(ការងារតំឡើងរន្ធា)បានបញ្ចប់អាណាត្តិការងារ៥ឆ្នាំ(សានហ្គោ)។ហើយ៦ខែបន្ទាប់ពីនោះនៅខែកញ្ញានេះពួកគេបានចាប់ផ្តើមបន្តជីវភាពជាការងារពលករជំនាញទៀត។

សហាជីពយើងខ្ញុំក៏បានចាប់ផ្តើមធ្វើការងារជាស្ថាប័នភ្នាក់ងារទទួលចុះឈ្មោះផងដែរ។ហើយក៏បានបង្កើតការងារមួយគឺ『ការតំរង់ទិសដៅជីវភាព』នៅថ្ងៃនោះផងដែរ។ដើម្បីបង្កើនភាពងាយស្រួលយល់សំរាប់ជនបរទេសសហាជីពបានពន្យល់ណែនាំពីច្បាប់ដែលសំខាន់ៗនឹងចាំបាច់ក្នុងការរស់នៅប្រទេសជប៉ុនដោយភ្ជាប់ជាមួយអ្នកបកប្រែពរូបប្រចាំនៅសហាជីពផ្ទាល់។